# កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចថ្នាក់តំបន់ទូលំទូលាយ RCEP និងផលប៉ះពាល់មកលើប្រជាជនក្រីក្រ និងស្ត្រី

RCEP គ្របដណ្តប់សេដ្ឋកិច្ចដល់ទៅ៣៨% នៃសេដ្ឋកិច្ចពិភពលោក

RCEP គ្របដណ្តប់ពាណិជ្ជកម្មដល់ទៅ ៣០%នៃពាណិជ្ជកម្មពិភពលោក



## ឯកជនភាវូបនីយកម្ម



RCEP លើកទឹកចិត្តអោយមានការប្រកួតប្រជែងនិងអ្នកចូលរួមពីវិស័យឯកជនអោយកាន់តែច្រើន និងកាត់បន្ថយនូវចំណាយសាធារណៈរបស់រដ្ឋ។ ឯកជនភាវូបនីយកម្ម គឺទៅលើគ្រប់វិស័យដូចជា សុខភាព ការអប់រំ ទឹក ភ្លើង និងសេវាសាធារណៈផ្សេងៗទៀតដែលបង្ហាញពីផលប៉ះពាល់ជាច្រើនដល់ប្រជាជនក្រីក្រ។ បញ្ហា៖ មានលុយទើបទទួលបានសេវា ( សុខភាព អប់រំ...) សេវាមានតម្លៃថ្លៃ

## កម្មសិទ្ធិបញ្ញាទៅលើឱសថ




RCEPអនុវត្តកម្មសិទ្ធិបញ្ញាទៅលើឱសថដែលអាចផ្តល់អំណាចអោយក្រុមហ៊ុនឱសថធំៗអាចកាន់កាប់ផ្តាច់មុខនូវការចែកចាយផ្គត់ផ្គង់ លក់ និងកំណត់តម្លៃថ្លៃនៅលើទីផ្សារឱសថ។ លើសពីនេះកម្មសិទ្ធិបញ្ញានិងការដាក់ប៉ាតង់ទៅលើឱសថអាចមានរយៈពេលលើសពី២០ឆ្នាំ ក្រុមហ៊ុនឱសថធំៗអាចនិងមានសិទ្ធិសុំបន្តរយៈពេលប៉ាតង់បានចាប់ពី៥ឆ្នាំឡើងទៅ។ បញ្ហា៖ លក់ថ្នាំតម្លៃថ្លៃដោយផ្តាច់មុខអ្នកក្រីក្រ និងអ្នកចំណូលមធ្យមមិនអាចទទួលបានថ្នាំ និង ថ្នាំតម្លៃថ្លៃ ( មហារីក រលាកថ្លើមសេ អេដស៍ ទឹកនោមផ្អែម គ្រុនចាញ់...)។

## ការដាក់ប៉ាតង់ទៅលើគ្រាប់ពូជនិងសំភារៈកសិកម្ម



RCEPជំរុញឲ្យប្រទេសដែរជាសមាជិកចូលរួមក្នុងUPOV 1991 ( កតិកាសញ្ញាអន្តរជាតិសម្រាប់ការការពារប្រភេទដំណាំថ្មី)។ ក្រោមសេចក្តីព្រាង របស់RCEP រដ្ឋាភិបាលនៃប្រទេសជាសមាជិកនិងអនុញ្ញាតឲ្យអ្នកវិនិយោគបរទេសមានសិទ្ធិក្នុងការកាន់កាប់ដីឬទិញដីបាន។ RCEP និងបង្កើនការដាក់ប៉ាតង់ទៅលើសំភារៈកសិកម្មមួយចំនួនទៀតដូចជាម៉ាស៊ីនសំរាប់ធ្វើស្រែ ថ្នាំគីមីសំរាប់ធ្វើកសិកម្មដែលមានតម្លៃថ្លៃ។ បញ្ហា៖សិទ្ធិកសិករត្រូវបានបំពានក្នុងការគ្រប់គ្រងគ្រាប់ពូជដំណាំដោយក្រុមហ៊ុនគ្រាប់ពូជ សំភារៈកសិកម្មថ្លៃ ប៉ះពាល់តម្លៃកសិផលក្នុងស្រុកធ្លាក់តំលៃ មិនអាចប្រកួតប្រជែងទំនិញនាំចូលគ្រាប់ពូជគ្រប់គ្រងដោយក្រុមហ៊ុន និងការកើននូវការប្រើជីគីមី ថ្នាំពុល...។

## ប្រព័ន្ធដោះស្រាយជម្លោះរវាងអ្នកវិនិយោគទុន និងរដ្ឋ




RCEPអនុវត្តប្រព័ន្ធដោះស្រាយជម្លោះរវាងអ្នកវិនិយោគទុន និងរដ្ឋដែលប្រព័ន្ធនេះអនុញ្ញាតឲ្យក្រុមហ៊ុនបរទេសប្តឹងទាមទារសំណងពីរដ្ឋរាប់លានដុល្លារនៅពេលដែលរដ្ឋាភិបាលធ្វើសកម្មភាពឬអនុវត្តកម្មវិធីគោលនយោបាយឬច្បាប់ទាំងឡាយណាក្នុងគោលបំណងបំរើប្រយោជន៍សាធារណៈដែលប៉ះពាល់ដល់ប្រាក់ចំនេញរបស់ពួកគេ។ បញ្ហា៖ រដ្ឋបាត់តួនាទីក្នុងការការពារប្រយោជន៍សាធារណៈ បរិស្ថាន...